# ៤.បណ្ដាតំបន់ IBA

ជំពូកនេះបង្ហាញអំពីចំណុចសំខាន់ៗដែលមាននៅក្នុងតំបន់និមួយៗនៃតំបន់សត្វស្លាបសំខាន់ៗ (IBA) ទាំង៤០កន្លែង ដែលត្រូវបានជ្រើសរើសនៅក្នុងប្រទេសកម្ពុជា ។ ការកត់សំគាល់ខាងក្រោមនេះគឺជាគន្លឹះមួយចំពោះផ្នែកដែលពាក់ព័ន្ធទាំងឡាយ ។

**នៅផ្នែកខាងលើ** (Heading)

**លេខកូដតំបន់** IBA៖ តំបន់ IBA និមួយៗមានលេខកូដតែមួយគត់ ។ លេខកូដទាំងអស់សម្រាប់តំបន់ IBA នៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ KH (ខ្មែរ) ហើយរួមមានពី KH001 រហូតដល់ KH040 ។

**ឈ្មោះតំបន់** IBA៖ តំបន់ IBA និមួយៗសុទ្ធតែមានឈ្មោះ ។ ឈ្មោះតំបន់ IBA ទាំងនោះត្រូវបានដាក់ដោយផ្អែកតាមឈ្មោះរបស់ស្រុកដែលតំបន់នោះស្ថិតនៅ ឬ តាមលក្ខណៈពិសេសភូមិសាស្ត្រដែលឃើញជាក់ស្តែងមាននៅទីកន្លែងនោះ ដូចជាទន្លេ ភ្នំ ឬ វាលភក់ ។

**លក្ខណៈវិនិច្ឆ័យ៖** លក្ខណៈវិនិច្ឆ័យតំបន់ IBA ដែលទីកន្លែងនិមួយៗឆ្លើយតបទៅនឹងតំបន់ IBA មានដូចខាងក្រោម៖

**ផ្ទៃដី៖** ផ្ទៃដីតំបន់ IBA ត្រូវបានគិតជាហិកតា ។ សម្រាប់តំបន់ IBA ទាំងអស់ ព្រំប្រទល់ជាក់លាក់មិនទាន់ត្រូវបានកំណត់ឡើយ ហើយទំហំផ្ទៃដីរបស់តំបន់និមួយៗគិតទៅតាមព្រំប្រទល់បានកំណត់ឱ្យតំបន់និមួយៗនោះ ។

**រយៈកំពស់៖** រយៈកំពស់ប្រហាក់ប្រហែលរបស់តំបន់ IBA ត្រូវបានគិតជាម៉ែត្រធៀបនឹងនីវ៉ូសមុទ្រ ។

**កូអរដោនេចំណុចកណ្ដាល៖** រយៈទទឹង និង រយៈបណ្ដោយនៃចំណុចកណ្ដាលរបស់តំបន់ IBA ត្រូវបានគណនាយកត្រឹមនាទី (Minute) ។

**ការពណ៌នាទូទៅ**

ផ្នែកនេះផ្ដោតលើសារៈសំខាន់នៃតំបន់សម្រាប់ការអភិរក្សសត្វស្លាប ជាពិសេសហេតុផលទាំងឡាយដែលពាក់ព័ន្ធទៅនឹងការជ្រើសរើសតំបន់ IBA និមួយៗ ។ មានពត៌មានសង្ខេបលើទីតាំងព្រំប្រទល់ លក្ខណៈសណ្ឋានដី អេកូឡូស៊ី និង សកម្មភាពគ្រប់គ្រងដែលមាននៅពេលបច្ចុប្បន្ន ។ លើសពីនេះទៀត លក្ខណៈសំខាន់ៗនៃប្រភេទសត្វស្លាបដែលមាននៅក្នុងតំបន់ IBA គឺត្រូវបានសង្ខេបយ៉ាងខ្លី ។

**ប្រភេទសត្វស្លាបសំខាន់ៗ**

ចំណាត់ថ្នាក់ប្រភេទទាំងអស់ A1 (ប្រភេទសត្វស្លាបទទួលរងការគំរាមកំហែងពិភពលោក) ចំណាត់ថ្នាក់ប្រភេទ A2 (ប្រភេទសត្វស្លាបមានតែនៅតាមតំបន់ជាក់លាក់) និង ចំណាត់ថ្នាក់ប្រភេទ A4 (ប្រភេទសត្វស្លាបរស់នៅក្នុងលក្ខណៈប្រមូលផ្តុំជាហ្វូងធំៗ) ដែលបានកត់ត្រាពីតំបន់ចាប់តាំងពីឆ្នាំ១៩៩២ ត្រូវបានចុះនៅក្នុងបញ្ជីឈ្មោះនេះ ។ សម្រាប់ប្រភេទនិមួយៗមានឈ្មោះជាភាសាខ្មែរ អង់គ្លេស និង ឈ្មោះវិទ្យាសាស្ត្រ រួមជាមួយលក្ខណៈវិនិច្ឆ័យ IBA ដែលប្រភេទទាំងនោះឆ្លើយតប ។ បណ្ដាប្រភេទសត្វស្លាបដែលមានវត្តមាននៅតាមតំបន់ IBA មិនច្បាស់លាស់ ប្រភេទមានវត្តមានជាក់លាក់តែមិនទៀងទាត់ទាក់ទងទៅនឹងចំនួនពិសេសរបស់វា និង ប្រភេទមួយចំនួនផ្សេងទៀតទទួលបានពីការកត់ត្រាជាប្រវត្តិសាស្ត្រមិនត្រូវបានចុះក្នុងបញ្ជីឡើយ ។ ប្រភេទទាំងនោះត្រូវបានបញ្ចូលក្នុងផ្នែកពិពណ៌នាទូទៅ ។

**ប្រភេទសត្វប្រមូលផ្តុំនៅក្នុងតំបន់មួយជាក់លាក់** (Biome-restricted species)

ចំនួននៃប្រភេទសត្វរស់នៅប្រមូលផ្ដុំក្នុងតំបន់មួយជាក់លាក់ក្នុងចំណោត់ថ្នាក់ប្រភេទ A3 ត្រូវបានចុះក្នុងបញ្ជីនៃតំបន់ជាក់លាក់ពាក់ព័ន្ធដែលមានចំនួន៤កន្លែង ។

**ប្រភេទសត្វបន្ទាប់បន្សំ** (Secondary species)

ប្រភេទពានរជាតិ, ដំរី និង ពពួកក្រចកជំពាម, អណ្ដើក កន្ធាយ និង ក្រពើ, និង ប្រភេទរុក្ខជាតិ ដែលបានកត់ត្រាត្រូវបានបញ្ចូលក្នុងបញ្ជីនៃតំបន់ IBA ។

**ការគំរាមកំហែងលើជីវៈចំរុះ និង អនុសាសន៍**

ការគំរាមកំហែងចំបងៗលើជីវៈចំរុះ និង បណ្ដាអនុសាសន៍នៃការគ្រប់គ្រងនៅតាមតំបន់ IBA និមួយៗត្រូវបានសង្ខេបយ៉ាងខ្លី ។ ពតិមានដែលបានយកចងក្រងត្រូវប្រមូលបានពីប្រភពមួយចំនួនរួមមាន របាយការណ៍មិនទាន់បោះពុម្ព និង បានបោះពុម្ពរួច និង ការចុះសិក្សាស្រាវជ្រាវផ្ទាល់ដល់ទីកន្លែង ។

**ឯកសារយោង**

ប្រភពឯកសារដែលត្រូវយកមកប្រើប្រាស់ ដើម្បីចងក្រងតំបន់សត្វស្លាបសំខាន់ៗក្នុងអត្ថបទនេះត្រូវបានចុះជាឯកសារយោងទាំងអស់ ។